សេចក្តីថ្លែងការណ៍រួម
ទិវាចងចាំ

# ខួប១០ឆ្នាំ នៃការបង្ក្រាបដោយហិង្សាមកលើកូដករ
# នៅមុខរោងចក្រយ៉ាកជីង និងផ្លូវវែងស្រែង

ថ្ងៃទី២ ដល់ ៣ ខែមករា ឆ្នាំ២០១៤ - ថ្ងៃទី២ ដល់ ៣ ខែមករា ឆ្នាំ២០២៤

---

អស់រយៈពេលពេល១០ឆ្នាំ នៃព្រឹត្តិការណ៍បង្ក្រាបមកលើក្រុមកូដករ នៅខាងមុខរោងចក្រយ៉ាកជីង និងផ្លូវវែងស្រែង ខណៈពេលដែលពួកគេកំពុងធ្វើការទាមទារតម្លើងប្រាក់ឈ្នួល ១៦០ដុល្លារ ដោយផ្អែកលើការសិក្សាស្រាវជ្រាវ និងតម្រូវការសេដ្ឋកិច្ច។ ក្រោយការចរចាប្រាក់ឈ្នួលមានភាពជាប់គាំង និងពុំទទួលបានការឆ្លើយតបទៅតាមតម្រូវការសេដ្ឋកិច្ច បានធ្វើឱ្យមានកម្មករជាច្រើននាក់ ធ្វើការតវ៉ាទូទាំងប្រទេស។ នៅថ្ងៃទី២ និងទី៣ ខែមករា ឆ្នាំ២០១៤ អាជ្ញាធរបានធ្វើការបង្ក្រាបទៅលើក្រុមកូដករដែលកំពុងប្រមូលផ្តុំធ្វើការទាមទារនៅមុខរោងចក្រយ៉ាកជីង និងផ្លូវវែងស្រែង យ៉ាងធ្ងន់ធ្ងរដោយប្រើប្រាស់គ្រាប់កាំភ្លើងពិតមកលើក្រុមកូដករ ដែលបានធ្វើឱ្យកម្មករចំនួន៤នាក់ បានស្លាប់ កម្មករម្នាក់បានបាត់ខ្លួនមកដល់ពេលបច្ចុប្បន្ន ចំណែកកម្មករចំនួន ៤៤នាក់ផ្សេងទៀត បានរងរបួស ខណៈមនុស្ស២៣នាក់ត្រូវបានចាប់ខ្លួនដាក់ពន្ធនាគារអស់រយៈពេល ០៥ខែ។ សូមរំលឹកឡើងវិញថា កម្មករដែលបានស្លាប់បាត់បង់ជីវិតរួមមានឈ្មោះ **លោក គីម ផាលាភ លោក សាម រ៉ាវី លោក យាន រិទ្ធី និងលោក ផេង កុសល។ ចំណែកយុវជន ខឹម សុផាត** ត្រូវបានគេប្រទះឃើញថា បានត្រូវគ្រាប់កាំភ្លើង និងត្រូវកម្លាំងប្រដាប់អាវុធបានលើករូបលោកដាក់រថយន្តបើកចេញទៅបាត់ពុំមានដំណឹងរហូតមកដល់បច្ចុប្បន្ន។

រយៈពេល១០ឆ្នាំមកនេះ យើងនៅតែចងចាំការលះបង់ សេចក្តីនឹករលឹក និងធ្វើការដឹងគុណដល់វិញ្ញាណក្ខ័ន្ធរបស់វីរៈកម្មករដែលបានបាត់បង់ជីវិតដោយការទាមទារប្រាក់ឈ្នួលសមរម្យ សម្រាប់លើកកម្ពស់ជីវភាព និងជីវិតថ្លៃថ្នូរសម្រាប់កម្មករកម្ពុជា ។

ក្នុងនាមជាជនរងគ្រោះ និងសាច់ញាតិ យើងខ្ញុំទាំងអស់គ្នាបានប្រារព្ធខួប១០ឆ្នាំនៃព្រឹត្តិការណ៍ សូមធ្វើការអំពាវនាវដល់រាជរដ្ឋាភិបាល ធ្វើការដោះស្រាយនូវបញ្ហាដែលបានកើតឡើងមកលើកម្មករ ខណៈពេលដែលពួកគេបានប្រើប្រាស់សិទ្ធិជាមូលដ្ឋានក្នុងការធ្វើកូដកម្ម និងយុត្តិធម៌ដល់កម្មករ និងជនរងគ្រោះពីការបង្ក្រាបដោយហិង្សា តាមរយៈ

១-ទម្លាក់បទចោទមកលើកម្មករ និងសកម្មជនសហជីព ដោយឥតលក្ខខណ្ឌ
២-ធ្វើការដាក់ទោសចំពោះសមត្ថកិច្ចដែលបានបង្ក្រាប និងប្រើប្រាស់អំពើហិង្សាមកដល់កម្មករ
៣-បន្តធ្វើការស៊ើបអង្កេតស្វែងរកជនរងគ្រោះដែលបានបាត់ខ្លួន
៤-ផ្តល់សំណងដល់គ្រួសារជនរងគ្រោះដែលបានស្លាប់ និងបាត់ខ្លួន រួមទាំងសំណងដល់កម្មករ ដែលបានចាប់ដាក់ពន្ធនាគារដោយភាពអយុត្តិធម៌ ឬប៉ះពាល់ផ្លូវចិត្ត និងខូចខាតផ្សេងៗ។

សេចក្តីថ្លែងការណ៍នេះគាំទ្រដោយ៖

១- សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ(IDEA)
២- សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា(CFSWF)
៣- សមាគមបណ្តាញយុវជនកម្ពុជា(CYN)
៤- សម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)
៥- សមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ (KSILA)
៦- សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (CTWUF)
៧- សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ (LRSU)
៨- អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)
៩- សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (LICADHO)
១០- សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
១១- គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
១២- សហព័ន្ធសហជីពឯករាជ្យ (ITUF)
១៣- សហព័ន្ធសហជីពសេរីកម្មករ នៃព្រះរាជាណាចក្រកម្ពុជា (FTUWKC)
១៤- មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)

តំណភ្ជាប់សម្រាប់គាំទ្រសេចក្តីថ្លែងការណ៍រួម៖ https://forms.gle/MrFENRqHr1ZHEY2H9